ក្រុមគ្រួសារចូលរួមក្នុងពិព័រណ៍ជម្រើសសាលារៀននៅទីលានខាងមុខ PCTA។

ទំនាក់ទំនង

ថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2022

ទស្សនៈអគ្គនាយក

សូមស្វាគមន៍មកកាន់ការបោះពុម្ពផ្សាយថ្មីបំផុតរបស់ព្រឹត្តិបត្រព័ត៌មាននៃមណ្ឌលសិក្សាធិការសាធារណៈព្រូវីដិន (PPSD) ប្រចាំពីរសប្តាហ៍ម្តង! ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ខកខានព្រឹត្តិបត្រព័ត៌មានរបស់យើង អ្នកអាចស្វែងរកការបោះពុម្ពផ្សាយកន្លងមកនៅលើគេហទំព័ររបស់មណ្ឌលសិក្សាធិការ ដែលមានភាសាជាច្រើន។

ការផ្តោតសំខាន់លេខមួយរបស់យើងនៅព្រូវីដិន គឺបង្កើនលទ្ធផលសម្រាប់សិស្សរបស់យើង។ ការតាំងចិត្តខ្លួនយើងឡើងវិញទៅកាន់គោលដៅនោះ គឺមានសារៈសំខាន់ជាងពេលណាទាំងអស់ ជាមួយនឹងផលប៉ះពាល់ដ៏ធំដែលជំងឺរាតត្បាតបានកើតមានលើសិស្ស និងការបាត់បង់ការសិក្សាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។

ប្រហែលជារង្វាស់ដែលល្អបំផុតនៃវឌ្ឍនភាពរបស់សិស្សគឺប្រព័ន្ធវាយតម្លៃការសិក្សា Rhode Island ឬ RICAS។ ជាមួយនឹងការធ្វើតេស្តចុងក្រោយបំផុតរបស់យើង យើងមានមោទនភាពដែលសាលាបឋមសិក្សា PPSD ស្ទើរតែទាំងអស់បានធ្វើឱ្យប្រសើរឡើងនូវពិន្ទុគណិតវិទ្យា RICAS ក្នុងឆ្នាំ 2022 បើធៀបនឹងឆ្នាំ 2021។

ជាការពិត PPSD បានជាសះស្បើយប្រហែល 60% នៃការបាត់បង់ការសិក្សាគណិតវិទ្យានៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ បើធៀបទៅនឹងលទ្ធផល RICAS ឆ្នាំ 2019។ កុំភ័ន្តច្រឡំ ពិន្ទុទាំងនេះស្ទើរតែមិនគ្រប់គ្រាន់ទេ ហើយយើងត្រូវតែបន្តធ្វើការកែលម្អ។ ប៉ុន្តែវាជាការសំខាន់ណាស់ដែលត្រូវដឹងថាយើងកំពុងរក្សាលំនឹងបន្ទាប់ពីជំងឺរាតត្បាត និងការកសាងវឌ្ឍនភាពដែលយើងចង់ឃើញ។

ចាប់ពីសប្តាហ៍ក្រោយ ក្រុមគ្រួសារនៅទូទាំងមណ្ឌលនឹងទទួលបានច្បាប់ចម្លងរឹងនៃរបាយការណ៍ពិន្ទុបុគ្គល RICAS (ISRs) របស់សិស្សរបស់ពួកគេចាប់ពីរដូវផ្ការីកឆ្នាំ 2022។ ច្បាប់ចម្លងរឹងនឹងត្រូវបានផ្ញើទៅផ្ទះជាមួយសិស្សម្នាក់ៗដោយសាលារៀនរបស់ពួកគេ។ មានលេខកូដ QR ថ្មីដែលនឹងផ្តល់ជាវីដេអូផ្ទាល់ខ្លួនអំពីពិន្ទុរបស់កូនអ្នក ជាភាសាដែលអ្នកនិយាយនៅផ្ទះ! សូមពិនិត្យមើលព័ត៌មានរបស់កូនអ្នកអំពីសិល្បៈភាសាអង់គ្លេស និងការវាយតម្លៃគណិតវិទ្យារបស់ពួកគេ។

សូមអរគុណជានិច្ចចំពោះភាពជាដៃគូរបស់អ្នកក្នុងការអប់រំសិស្សរបស់អ្នក។ ខ្ញុំទន្ទឹងរង់ចាំធ្វើការរួមគ្នាដើម្បីបន្តបង្កើនពិន្ទុរបស់យើង ហើយសំខាន់បំផុតគឺលទ្ធផលសិស្សរបស់យើង។

អគ្គនាយក Javier Montañez Ed. D. ថ្លែងក្នុងពិធីបើកការដ្ឋាននៅសាលាបឋមសិក្សា D'Abate ថ្មីៗនេះ។

ការធ្វើបច្ចុប្បន្នភាពរបស់មណ្ឌល

ការកសាងឡើងវិញសាលារៀនសាធារណៈព្រូវីដិន

ជាលើកដំបូងដែលមិនធ្លាប់មាន ព្រូវីដិនមានទឹកប្រាក់ជាង $500 លានដុល្លារ ដើម្បីវិនិយោគក្នុងការធ្វើទំនើបកម្មអគារសិក្សាសាធារណៈរបស់យើង។ នេះគឺជាឱកាសមួយដើម្បីកែទម្រង់មណ្ឌលឡើងវិញ និងបង្កើតបរិយាកាសសិក្សានៅសតវត្សរ៍ទី 21 សម្រាប់សិស្ស និងអ្នកអប់រំ។ មតិកែលម្អសហគមន៍មានសារៈសំខាន់ចំពោះការប្រើប្រាស់មូលនិធិទាំងនេះដោយជោគជ័យ ដូច្នេះ PPSD បានរៀបចំវគ្គចូលរួមសហគមន៍ជាច្រើនដោយមានពីរបន្ថែមទៀតនឹងមកដល់នៅសប្តាហ៍ក្រោយ។ វគ្គនិម្មិតទាំងនេះនឹងធ្វើឡើងនៅលើZoom នៅថ្ងៃ**ច័ន្ទ ទី 5 ខែធ្នូ** និង**ថ្ងៃព្រហស្បតិ៍ ទី 8 ខែធ្នូ**ចាប់ពី**ម៉ោង 6 ល្ងាច ដល់ម៉ោង 7:30 យប់**។ ប្រសិនបើអ្នកមិនអាចចូលរួមបានទេ វគ្គនិម្មិតមួយក្នុងចំណោមវគ្គនិម្មិតទាំងនេះនឹងត្រូវបានថតទុក និងបង្ហោះនៅលើគេហទំព័រ PPSD ហើយអ្នកអាចផ្ញើមតិកែលម្អសហគមន៍នៅលើwww.rebuildpvdschools.com ដើម្បីដាក់សំណួរ ឬមតិរបស់អ្នក។

ថ្ងៃចេញមុនម៉ោងនៅថ្ងៃទី 14 ខែធ្នូ

នេះជាសារំលឹកក្សរវាយមួយដែល**សាលារៀនទាំងអស់**នឹងមានការចេញមុនពីរម៉ោងប្រចាំខែបន្ទាប់របស់ពួកគេនៅ**ថ្ងៃពុធ ទី 14 ខែធ្នូ** សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ ក្រុមគ្រួសារអនុវិទ្យាល័យគួរកត់សម្គាល់ថា នេះគឺខុសពីម៉ោងចេញថ្ងៃពុធប្រចាំសម្រាប់សិស្សសាលាមធ្យមសិក្សា។ អនុវិទ្យាល័យនឹងត្រូវចេញនៅម៉ោង 12:40 រសៀល នៅថ្ងៃទី 14 ខែធ្នូ ដើម្បីអនុញ្ញាតឱ្យរថយន្តក្រុងរត់ទាន់ពេលសម្រាប់សាលារៀនផ្សេងទៀតដែលត្រូវបានចេញមុននៅថ្ងៃនោះ។ ក្រុមគ្រួសារក៏គួរចងចាំផងដែរដើម្បីពិនិត្យមើលកាលវិភាគពីរដងនៅមជ្ឈមណ្ឌលកម្មសាន្តក្នុងមូលដ្ឋាន ដោយសារមួយចំនួនប្រហែលជាមិនទាន់បើករហូតដល់ម៉ោង 3 រសៀល ដោយសារតែការរៀបចំបុគ្គលិក។

ជម្រើសសាលារៀនឆ្នាំ 2022

ឆ្នាំនេះជាលើកដំបូងដែលមិនធ្លាប់មាន សាលារៀនសាធារណៈព្រូវីដិនទាំងអស់បានប្រមូលផ្តុំគ្នានៅក្នុងទីលានខាងមុខ PCTA សម្រាប់**ពិព័រណ៍ជម្រើសសាលារៀន**ប្រចាំឆ្នាំ។ ព្រឹត្តិការណ៍នេះគឺជាឱកាសដ៏អស្ចារ្យសម្រាប់ក្រុមគ្រួសារ និងសិស្សានុសិស្សដើម្បីស្វែងយល់អំពីកម្មវិធី ឱកាស និងអត្ថតពលិកដ៏អស្ចារ្យនៅក្នុងសាលារៀនរបស់យើង បូករួមទាំងគម្រោងសាងសង់នាពេលខាងមុខ។

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានខកខានពិព័រណ៍ជម្រើសសាលារៀន អ្នកអាចស្វែងយល់បន្ថែមអំពីសាលារៀនទាំងអស់របស់យើងដោយចូលទៅកាន់គេហទំព័រ https://www.providenceschools.org/schoolchoice ដើម្បីមើលប្រវត្តិរូបរបស់សាលារៀនជាភាសាជាច្រើន!

សមភាពនៅក្នុងសាលារៀនសាធារណៈព្រូវីដិន

សន្និសិទភាពជាអ្នកដឹកនាំសមធម៌សិស្ស RESPECT

នៅថ្ងៃទី 16 ខែវិច្ឆិកា ឆ្នាំ 2022 ប្រវត្តិសាស្ត្រត្រូវបានធ្វើឡើងនៅព្រូវីដិន នៅពេលដែលអ្នកដឹកនាំសិស្សចំនួន 60 នាក់ មកពីអនុវិទ្យាល័យ និងវិទ្យាល័យព្រូវីដិនរបស់យើងបានជួបគ្នានៅ Downtown Providence Marriott សម្រាប់**សន្និសិទភាពជាអ្នកដឹកនាំសមធម៌សិស្ស RESPECT** ជាលើកដំបូងដែលមិនធ្លាប់មាន។ **Mr. William Winfield** បានដើរតួជាវាគ្មិនសំខាន់ និងកំណត់ដំណាក់កាលសម្រាប់ការចូលរួម កិច្ចសហការ និងការដោះស្រាយបញ្ហាយ៉ាងសីជម្រៅ។ សិស្សបានចំណាយពេលកំណត់ការយល់ដឹងរួមរបស់ពួកគេអំពីអត្ថន័យនៃសមធម៌ ភាពចម្រុះ និងបរិយាប័ន្ន។ ពួកគេបានបង្ហាញពីទស្សនវិស័យសម្រាប់ភាពជោគជ័យរបស់ពួកគេ និងកំណត់បញ្ហាប្រឈមទាំងនោះ ដែលជាឧបសគ្គដល់ភាពជោគជ័យរបស់ពួកគេ។ បន្ទាប់មកអ្នកដឹកនាំសិស្សបានចំណាយពេលរសៀលដើម្បីបង្កើតផែនការសកម្មភាពដែលពួកគេនឹងប្រើដើម្បីចូលរួមជាមួយមនុស្សពេញវ័យសម្រាប់គ្រប់សាលារៀនដើម្បីជះឥទ្ធិពលលើការផ្លាស់ប្តូរ។ នេះគឺជាផ្នែកទីមួយនៃស៊េរីបីផ្នែកស្តីពីភាពជាអ្នកដឹកនាំសិស្សចំនួនដែលបានគ្រោងទុកសម្រាប់ឆ្នាំសិក្សានេះ។ ខាងក្រោមនេះគឺជាព្រឹត្តិការណ៍ដែលបានគ្រោងទុកបន្ថែមសម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យសមធម៌ និងភាពចម្រុះតាមរយៈលេខ 401.456.9100 ext. 11358 ឬផ្ញើអ៊ីមែលទៅ equity@ppsd.org ។



សិស្ស	គ្រូបង្រៀន/សហគមន៍/មាតាបិតា	អ្នកដឹកនាំសាលារៀន
សន្និសិទភាពជាអ្នកដឹកនាំសមធម៌សិស្ស RESPECT ផ្នែកទី 1៖ ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2022	វគ្គការងារអប់រំដែលឆ្លើយតបតាមវប្បធម៌ និងប្រវត្តិសាស្ត្រជាមួយ Dr. Gholdy Muhammad ផ្នែកទី 1៖ ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2022	វគ្គការងារភាពជាអ្នកដឹកនាំផ្តោតលើសមធម៌ជាមួយ Dr. Mark Gooden ផ្នែកទី 1៖ ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2022
សន្និសិទភាពជាអ្នកដឹកនាំសមធម៌សិស្ស RESPECT ផ្នែកទី 2៖ ថ្ងៃទី 2 ខែកុម្ភៈ ឆ្នាំ 2023	វគ្គការងារអប់រំដែលឆ្លើយតបតាមវប្បធម៌ និងប្រវត្តិសាស្ត្រជាមួយ Dr. Gholdy Muhammad ផ្នែកទី 2៖ ថ្ងៃទី 31 ខែឧសភា ឆ្នាំ 2023	វគ្គការងារភាពជាអ្នកដឹកនាំផ្តោតលើសមធម៌ជាមួយ Dr. Mark Gooden ផ្នែកទី 2៖ ថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2023
សន្និសិទភាពជាអ្នកដឹកនាំសមធម៌សិស្ស RESPECT ផ្នែកទី 3៖ ថ្ងៃទី 15 ខែឧសភា ឆ្នាំ 2023	ការអភិវឌ្ឍន៍ទម្លាប់ក្នុងចិត្ត៖ ចូលកាន់តែស៊ីជម្រៅជាមួយនឹងការបង្រៀនដែលឆ្លើយតបតាមវប្បធម៌ និងប្រវត្តិសាស្ត្រ (ជំនាន់គាំទ្រ) ខែវិច្ឆិកា ដល់ខែមិថុនា ឆ្នាំ 2023	
	ការបង្កើតមូលដ្ឋានមួយសម្រាប់ជំនាន់សមធម៌ក្នុងការអនុវត្តរបស់អ្នក (ជំនាន់គាំទ្រ) ខែមករា ដល់ខែមិថុនា ឆ្នាំ 2023	
	ការពង្រឹងការអនុវត្តសមធម៌ដើម្បីសិក្សា និងដឹកនាំ (ជំនាន់គាំទ្រ) ខែមករា ដល់ខែមិថុនា ឆ្នាំ 2023	

ការអបអរសាទរដល់សិស្ស

សិស្សដែលមានទេពកោសល្យ និងឧស្សាហ៍ព្យាយាមរបស់យើងកំពុងធ្វើរឿងដ៏អស្ចារ្យជារៀងរាល់ថ្ងៃ។ ទាំងនេះគឺជាឧទាហរណ៍ជាក់ស្តែងពីរបី។

សិស្ស PCTA ធ្វើការរចនាខិត្តប័ណ្ណជម្រើសសាលារៀន

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសិស្សានុសិស្សនៅក្នុងកម្មវិធីក្រាហ្វិកនៅ **PCTA** ដែលបានរចនាខិត្តប័ណ្ណដែលបានប្រើសម្រាប់ពិព័រណ៍ជម្រើសសាលារៀន PPSD នៅឆ្នាំនេះ! ជាផ្នែកនៃគម្រោង សិស្សក៏អាចរៀនអំពីអ្នកក្រុមចំណែកដ៏សំខាន់ក្នុងឧស្សាហកម្មរចនាក្រាហ្វិក ហើយអាចបង្ហាញការស្រាវជ្រាវរបស់ពួកគេតាមរយៈការរចនាផ្សេងៗគ្នា។ កម្មវិធីរចនាក្រាហ្វិកគឺគ្រាន់តែជាកម្មវិធីមួយក្នុងចំណោមកម្មវិធីដ៏អស្ចារ្យជាច្រើនដែល PCTA មានផ្តល់ជូន។



ការប្រកួតបាល់ទះនារីវគ្គផ្តាច់ព្រ័ត្រ

សូមចូលរួមអបអរសាទរដល់**ក្រុមបាល់ទះនារីវិទ្យាល័យ Hope** ដែលពួកគេបានជាប់ចំណាត់ថ្នាក់លេខរៀងទី IV ទូទាំងរដ្ឋក្នុងឆ្នាំនេះ។ វាជារដូវកាលដែលមានការប្រកួតប្រជែងខ្លាំង ហើយពួកគេបានតស៊ូយ៉ាងខ្លាំងរហូតដល់ទីបញ្ចប់។ យើងមិនអាចរង់ចាំមើលថាតើBlue Wave អាចសម្រេចបាននៅរដូវកាលក្រោយទេ!

គិតដូចអ្នកបុរាណវិទ្យា

អនុវិទ្យាល័យ West Broadway សហការជាមួយ**វិទ្យាស្ថាន Joukowsky នៃសាកលវិទ្យាល័យ Brown សម្រាប់បុរាណវិទ្យា** និង**សារមន្ទីរ RISD** កំពុងផ្តល់ជូននូវកម្មវិធី "គិតដូចអ្នកបុរាណវិទ្យា" សម្រាប់សិស្សថ្នាក់ទី 6។ សិស្សមានឱកាសស្វែងយល់ពីវត្ថុបុរាណផ្សេងៗដែលបាននាំយកមក ហើយអាចស្វែងយល់បន្ថែមអំពីវិស័យបុរាណវិទ្យា។



មិត្តភក្តិសម្រាប់ការអាន

សិស្ស Pre-K នៅ**បឋមសិក្សា Young Woods** សូមថ្លែងអំណរគុណចំពោះមិត្តភក្តិសម្រាប់ការអានថ្នាក់ទី 5 របស់ពួកគេដែលបានចូលមកក្នុងថ្នាក់រៀនដើម្បីធ្វើសកម្មភាពជាមួយពួកគេក្មេងៗនៅខែនេះ។ គ្រូបង្រៀន Ms. Withers និង Ms. Corcoran បានរៀបចំផែនការសកម្មភាពមួយដែលរួមបញ្ចូលសំណុំជំនាញផ្សេងៗគ្នាជាច្រើនដូចជាការដោះស្រាយបញ្ហា ជំនាញវិចិត្រសិល្បៈ ការស្តាប់ គណិតវិទ្យា និងអក្ខរកម្ម។ សូមអរគុណសម្រាប់ការអានជាមួយសិស្ស Pre-K របស់យើង!

អបអរសាទរបេតិកភណ្ឌការនិយាយភាសាអេស្ប៉ាញ

សិស្សានុសិស្ស និងបុគ្គលិកនៅ**អនុវិទ្យាល័យ Gilbert Stuart** បានធ្វើការងារដ៏អស្ចារ្យមួយដោយគោរពដល់បេតិកភណ្ឌការនិយាយភាសាអេស្ប៉ាញនៃសហគមន៍សាលារៀនរបស់ពួកគេជាមួយនឹងក្បួនដង្ហែ និងការអបអរសាទរ! បុគ្គលិកជាច្រើនមានគ្រូបង្រៀន អ្នកគ្រប់គ្រង អាណាព្យាបាល បុគ្គលិកអាហារថ្ងៃត្រង់ អ្នកទំនាក់ទំនងសហគមន៍ និងអ្នកសម្របសម្រួលវប្បធម៌បានចូលរួម។ ប្រពៃណីប្រចាំឆ្នាំនេះបានក្លាយជាផ្នែកមួយនៃសហគមន៍ Gilbert Stuart ហើយយើងមិនអាចរង់ចាំសម្រាប់ការប្រារព្ធពិធីនៅឆ្នាំក្រោយបានទេ!



ចំណាប់អារម្មណ៍របស់បុគ្គលិក

ស្គាល់អ្នកធ្វើការដ៏អស្ចារ្យជាមួយសិស្សរបស់យើងជារៀងរាល់ថ្ងៃ!

Bianka Medeiros

គ្រូបង្រៀនថ្នាក់ទីបី

មានទីតាំងនៅ៖ **សាលាបឋមសិក្សា George J. West**

បានចូលរួមជាមួយ PPSD នៅក្នុង៖ **2013**

តើអ្វីបានធ្វើឱ្យអ្នកចង់បង្រៀនថ្នាក់ទីបី?

ខ្ញុំស្រលាញ់ថ្នាក់ទីបី! វាជាឆ្នាំដែលពិសេស – សិស្សមានភាពឯករាជ្យ ប៉ុន្តែពួកគេនៅតែត្រូវការអ្នក។ វាជាឆ្នាំដែលពួកគេពិតជាចាប់ផ្តើមអនុវត្តចំណេះដឹងក្នុងការអាន ហើយពួកគេប្តូរពីរៀនអានទៅអានដើម្បីរៀន។ រឿងដែលគួរឱ្យរំភើបចាប់ផ្តើមកើតឡើងនៅពេលដែលពួកគេរៀនជំនាញថ្មី ហើយអាចអនុវត្តជាក់ស្តែងបាន។ ខ្ញុំចូលចិត្តវា ព្រោះវាក៏ជាឆ្នាំដែលអ្នកចាប់ផ្តើមកំណត់អត្តសញ្ញាណកុមារ ដែលអាចត្រូវការការគាំទ្របន្ថែម ដូច្នេះអ្នកអាចជួយរៀបចំពួកគេឱ្យទទួលបានជោគជ័យ។

តើអ្នករៀបរាប់ការងាររបស់អ្នកដល់មនុស្ស ដែលមិនធ្វើការក្នុងវិស័យអប់រំយ៉ាងដូចម្តេចដែរ?

ក្នុងនាមជាគ្រូបង្រៀនម្នាក់ អ្នកត្រូវតែត្រៀមខ្លួនឱ្យបានឆាប់ពេលដែលកុមារចូលមក។ ការងារមួយចំនួនអ្នកអាចមានភាពងាយស្រួល ប៉ុន្តែនៅទីនេះអ្នកមានកុមារចំនួន 26 នាក់ កំពុងស្វែងរកចាមពេលដែលអ្នកមានមកជាមួយ។ អ្នកមិនដឹងថាសិស្សចូលមកជាមួយអ្វីទេ ដូច្នេះវាជាការសំខាន់ក្នុងការចូលរួមជាមួយពួកគេជានិច្ចនៅពេលព្រឹក។ វាមិនមែនជាការងារដែលអ្នកអាចធ្វើបានដោយមិនបានត្រៀមខ្លួននោះទេ។ ផ្នែកនៃការរៀបចំផែនការ និងការរៀបចំការងាររបស់ខ្ញុំគឺធ្វើឡើងនៅខាងក្រៅពេលការងារ។ យប់មិញ ខ្ញុំបានកែការធ្វើតេស្ត ហើយថ្ងៃនេះ យើងបានប្រើប្រាស់ពួកវា ដើម្បីរៀនពីរបៀបប្រើយុទ្ធសាស្ត្ររបស់យើងឱ្យកាន់តែមានប្រសិទ្ធភាព។ រាល់ការវិភាគ ការឆ្លុះបញ្ចាំង និងយុទ្ធសាស្ត្ររបស់ខ្ញុំកើតឡើងបន្ទាប់ចេញពីសាលារៀន – តើអ្វីបានដំណើរការល្អ និងតើអ្វីអាចប្រសើរជាងនេះ? ខ្ញុំតែងតែគិតរឿងនោះក្នុងគំនិតរបស់ខ្ញុំ ហើយព្យាយាមកែលម្អការអនុវត្តរបស់ខ្ញុំ។

"ខ្ញុំរីករាយនឹងការងាររបស់ខ្ញុំ ហើយខ្ញុំក៏សប្បាយដែរ ប៉ុន្តែខ្ញុំដឹងថាវាសំខាន់ប៉ុណ្ណា។ នេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតដែលនៅសល់របស់ពួកគេ" ។

តើអ្នកចង់ឱ្យមនុស្សជាច្រើនដឹងអ្វីខ្លះអំពីការធ្វើជាគ្រូបង្រៀន?

សម្រាប់ខ្ញុំ អនាគតគឺស្ថិតនៅក្នុងដៃរបស់ខ្ញុំ។ ប្រសិនបើសិស្សមិនទទួលបានជំនាញ និងយុទ្ធសាស្ត្រទាំងនេះ មុនពេលពួកគេចាកចេញពីថ្នាក់ទីបីនោះ ពួកគេមិនត្រូវបានរៀបចំសម្រាប់ភាពជោគជ័យនោះទេ។ ខ្ញុំរីករាយនឹងការងាររបស់ខ្ញុំ ហើយខ្ញុំក៏សប្បាយដែរ ប៉ុន្តែខ្ញុំដឹងថាវាសំខាន់ប៉ុណ្ណា។ នេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតដែលនៅសល់របស់ពួកគេ។

ខ្ញុំខំប្រឹងយល់ដឹងក្នុងនាមជាសិស្សខ្លួនឯង ហើយខ្ញុំនិយាយភាសាទីពីរ ហើយខ្ញុំឃើញខ្លួនឯងនៅក្នុងសិស្សរបស់ខ្ញុំ។ ការផ្តោតអារម្មណ៍របស់ខ្ញុំគឺដើម្បីឱ្យកុមាររបស់ខ្ញុំចូលចិត្តការរៀនសូត្រ ហើយដឹងថាវាមិនអីទេក្នុងការធ្វើខុស។ នៅពេលដែលយើងធ្វើខុស ហើយយល់កន្លែងដែលយើងខុស នោះហើយជារបៀបដែលយើងបង្កើតការរៀនសូត្រថ្មី។ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកសាងផ្នត់គំនិតរីកចម្រើន ឱ្យពួកគេរៀនចាប់យកឱកាស និងទទួលយកមតិកែលម្អពីអ្នក។ ការសន្ទនាទាំងនោះគឺជាកន្លែងដែលអ្នកយល់ពីរឿងទាំងនោះ ហើយនោះគឺជារង្វាន់ដ៏អស្ចារ្យបំផុតមួយ។

តើឆ្នាំនេះមានចំណុចពិសេសអ្វីខ្លះមកដល់ពេលនេះ?

អ្នកអាចឃើញឥទ្ធិពលដែល COVID មានលើថ្នាក់សិក្សាដែលខ្ញុំមានក្នុងឆ្នាំនេះ ទាក់ទងនឹងការសិក្សា និងជំនាញខាងអារម្មណ៍សង្គម។ យើងបានខិតខំយ៉ាងខ្លាំងលើទម្លាប់ ការរំពឹងទុក និងការកសាងកម្លាំង។ ខ្ញុំមានអារម្មណ៍ថាយើងកំពុងចាប់ផ្តើមធ្វើប្រសើរឡើង ហើយវាជារង្វាន់។ ពីរបីខែដំបូងគឺពិបាក ប៉ុន្តែយើងបានបង្កើតវឌ្ឍនភាពរីកចម្រើនជាច្រើនជាមួយគ្នា។ វាពិតជាល្អណាស់ដែលឃើញការផ្លាស់ប្តូរសមត្ថភាពរបស់ពួកគេក្នុងការធ្វើការឥឡូវនេះ និងរបៀបដែលពួកគេកំពុងកសាងភាពរឹងមាំនោះ ដើម្បីគាំទ្រដល់ការរំពឹងទុកកម្រិតថ្នាក់។

តើអ្នកទន្ទឹងរង់ចាំអ្វីសម្រាប់ឆ្នាំដែលនៅសល់?

ពេលឃើញសិស្សរបស់ខ្ញុំរីកចម្រើនឥឡូវពួកគេកំពុងទទួលបានវា។ យើងមើលទិន្នន័យ និងពិន្ទុជាមួយគ្នា ហើយសិស្សរបស់ខ្ញុំដឹងថាការរីកចម្រើនមើលទៅបែបណា។ ខ្ញុំជាអ្នកជឿជាក់ដ៏ធំមួយរូបក្នុងការឱ្យសិស្សរបស់ខ្ញុំធ្វើការកាន់កាប់ភាពជាម្ចាស់នៃការអប់រំរបស់ពួកគេ ដូច្នេះពួកគេយល់ពីសារៈសំខាន់ និងអាចចាប់ផ្តើមកំណត់គោលដៅសម្រាប់ខ្លួនពួកគេ។

ខ្ញុំក៏ចូលចិត្តធ្វើការជាមួយមិត្តរួមការងាររបស់ខ្ញុំដែរ! ខ្ញុំមិនអាចធ្វើការងារនេះដោយគ្មានពួកគេទេ។ ក្រុមការងាររដ្ឋបាលរបស់យើងក៏គាំទ្រផងដែរ។ ការងារអាចមានភាពរញ៉េរញ៉ៃ ប៉ុន្តែយើងនៅទីនេះធ្វើការដោយការព្យាយាមតាមដែលអាចធ្វើបានដើម្បីផ្តល់ឱ្យសិស្សរបស់យើងនូវការអប់រំដ៏ល្អបំផុតដែលអាចធ្វើទៅបាន។ យើងមានមិត្តរួមក្រុម និងគ្រូបង្រៀនថ្មីមួយចំនួននៅទីនេះនៅព្រូវីដិន។ យើងបញ្ចេញ និងផ្តល់គំនិតឱ្យគ្នាទៅវិញទៅមក រៀបចំផែនការរួមគ្នា ហើយសហគមន៍នៅទីនេះនៅ West គឺអស្ចារ្យណាស់។

វាជាដំណឹងដ៏ល្អ៖ PPSD នៅក្នុងសារព័ត៌មាន

- ការផ្តោតលើសហគមន៍៖ Natalie Fleming ចូលរួម 12 News ដើម្បីពិភាក្សាអំពីការគាំទ្រសុខភាពផ្លូវចិត្តរបស់សិស្ស
WPRI, ថ្ងៃទី 10 ខែវិច្ឆិកា
- សិស្សថ្នាក់ទី 8 របស់ព្រូវីដិនទាំងអស់បានផ្តល់ការប្រលងចូល HS Classical។ កាលបរិច្ឆេទថ្មី, ការស្នាក់នៅ
ព័ត៌មានថ្ងៃនេះ RI, ថ្ងៃទី 9 ខែវិច្ឆិកា
- អ្នកចិត្តសាស្ត្រសាលាបឋមសិក្សា Young Woods និយាយអំពីវិបត្តិសុខភាពផ្លូវចិត្តកន្លងមក
WJAR, ថ្ងៃទី 3 ខែវិច្ឆិកា
- អគ្គនាយកព្រូវីដិនមានផែនការជួសជុលសាលារៀនដែលមិនសូវដំណើរការ
វិទ្យុសាធារណៈ, ថ្ងៃទី 2 ខែវិច្ឆិកា
- វិទ្យាល័យ Hope ទទួលបានការលើកស្ទួយ ដោយសារការខិតខំប្រឹងប្រែងបន្តដើម្បីធ្វើទំនើបកម្មសាលារៀនទូទាំងរដ្ឋ
ABC6, ថ្ងៃទី 1 ខែវិច្ឆិកា

នៅជុំវិញមណ្ឌល

ពីសិស្ស MLL ទៅនាយក PPSD

ជួបជាមួយ Rosario Johnson **នាយកសាលានៅ**សាលាបឋមសិក្សា Frank D. Spaziano។ Rosario និងគ្រួសាររបស់នាងបានផ្លាស់ទៅសហរដ្ឋអាមេរិកពី Ecuador ហើយនាងបានចាប់ផ្តើមទៅសាលារៀននៅ New Jersey មុនពេលផ្លាស់ទៅព្រូវីដិនជាមួយគ្រួសាររបស់នាងនៅពេលនាងរៀនថ្នាក់ទីបី។ នាងបានបន្តការសិក្សារបស់នាងនៅ PPSD ហើយបានបញ្ចប់ការសិក្សានៅវិទ្យាល័យ Classical។ ក្នុងនាមជាអតីតសិស្ស MLL នាងបាននិយាយថានាងមានអរគុណចំពោះកម្មវិធីដែល PPSD ត្រូវផ្តល់អាហារដល់សិស្ស MLL ដូចដែលពួកគេបានជួយនាងនៅពេលនាងនៅសាលារៀន។

គន្លឹះសុវត្ថិភាពតាមអ៊ីនធឺណិតសម្រាប់រដូវកាលវិស្សមកាល

នាយកដ្ឋានព័ត៌មានវិទ្យានៅសាលារៀនសាធារណៈព្រូវីដិន លើកទឹកចិត្តអ្នកគ្រប់គ្នាឱ្យទិញទំនិញលើតាមអ៊ីនធឺណិតឆ្លាតវៃ និងមានសុវត្ថិភាពក្នុងរដូវកាលឈប់សម្រាកនេះ ជាមួយនឹងគន្លឹះសុវត្ថិភាពសាមញ្ញមួយចំនួនពីមជ្ឈមណ្ឌលសម្រាប់សុវត្ថិភាពអ៊ីនធឺណិត។ ដូចជាជំហានតូចៗ ដូចជាការជៀសវាងប្រព័ន្ធ WiFi សាធារណៈ ការប្រុងប្រយ័ត្នជាមួយនឹងការផ្តល់ជូនដែលមើលទៅល្អពេកដើម្បីក្លាយជាការពិត និងការប្រើពាក្យសម្ងាត់មានសមត្ថភាពខ្លាំងអាចជាភាពខុសគ្នារវាងការទិញទំនិញដោយសុវត្ថិភាព និងការធ្លាក់ចូលទៅក្នុងការលួចអត្តសញ្ញាណ!



គាំទ្រសុខភាពផ្លូវចិត្តរបស់សិស្ស និងគ្រួសារ

នៅក្នុងខែនេះ ការិយាល័យគាំទ្រសិស្ស PPSD និងនាយកដ្ឋានដែលទើបបង្កើតថ្មីនៃការអប់រំអារម្មណ៍សង្គម និងសុខភាពផ្លូវចិត្តបានចាប់ដៃគូជាមួយមន្ទីរពេទ្យ Bradley ដើម្បីជួយដល់ការបន្តវឌ្ឍនភាពក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ការសិក្សាពីអារម្មណ៍សង្គម (SEL) និងសុខភាពផ្លូវចិត្តនៅទូទាំងប្រព័ន្ធពហុកម្រិតនៃការគាំទ្រ (MTSS) ។ តាមរយៈជំនួយគម្រោង AWARE ចុងក្រោយបង្អស់របស់ PPSD អ្នកសម្របសម្រួលពេញម៉ោងនឹងត្រូវបានជួលឱ្យធ្វើការជាមួយនាយក SEL និងសុខភាពផ្លូវចិត្ត និងចិត្តវិទ្យាសាលារៀន និងអ្នកឯកទេសខាងសង្គមកិច្ចសាលា។ ឱកាសថ្មីនេះ និងភាពជាដៃគូជាមួយ**មន្ទីរពេទ្យ Bradley** នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់យុវជន ក្រុមគ្រួសារ និងសាលារៀនរបស់ព្រូវីដិន ដោយជួយជំរុញវឌ្ឍនភាពក្នុងការកសាងការយល់ដឹងអំពីសុខភាពផ្លូវចិត្ត ការពង្រឹងចំណេះដឹងផ្នែកសុខភាពផ្លូវចិត្ត និងការទទួលបានសេវាកម្មសុខភាពផ្លូវចិត្ត និងអាកប្បកិរិយាជាបន្តបន្ទាប់។ ចូលមើលគេហទំព័ររបស់យើងដើម្បីស្វែងយល់បន្ថែមអំពីសេវាកម្មដ៏មានតម្លៃដែលផ្តល់ដោយអ្នកជំនាញសុខភាពផ្លូវចិត្តរបស់សាលា។



នាយកសាលាព្រូវីដិនបានទទួលស្គាល់នៅលើឆាកជាតិ

សមាគមជាតិនៃនាយកសាលាអនុវិទ្យាល័យបានផ្តល់កិត្តិយសដល់នាយកសាលាកំពូល និងជំនួយការនាយកសាលាក្នុងប្រទេសក្នុងខែនេះ។ ក្នុងចំណោមនោះមាន**នាយកសាលាប្រចាំឆ្នាំ 2022 របស់ Rhode Island, Scott Barr នៃវិទ្យាល័យ Classical** ព្រមទាំង**ជំនួយការនាយកសាលាប្រចាំឆ្នាំ 2022 របស់ Rhode Island, Renee Walker នៃវិទ្យាល័យ Central**។ អ្នកទាំងពីរស្ថិតនៅ Washington, D.C. ក្នុងខែនេះ ដើម្បីទទួលបានកិត្តិយសសម្រាប់តួនាទីរបស់ពួកគេជាអ្នកគ្រប់គ្រងដ៏អស្ចារ្យ។ សូមអបអរសាទរដល់នាយកសាលា Barr និងជំនួយការនាយកសាលា Walker ហើយសូមអរគុណចំពោះអ្វីដែលអ្នកបានធ្វើក្នុងការដឹកនាំសិស្ស និងអ្នកអប់រំរបស់យើង!

WORLD SERIES MVP ត្រលប់មកផ្ទះវិញ

2022 ALCS និង World Series MVP និង Jeremy Peña ដែលបានបញ្ចប់ការសិក្សានៅវិទ្យាល័យ Classical នៅឆ្នាំ 2015 បានត្រឡប់ទៅផ្ទះនៅព្រូវីដិនកាលពីចុងសប្តាហ៍មុន និងបានស្វាគមន៍អ្នកគាំទ្រនៅ PCTA។ នៅឆ្នាំនេះ កីឡាករថ្មីជា shortstop ក៏បានឈ្នះស្រោមដៃមាស និងមានឈ្មោះនៅរដូវកាលដ៏អស្ចារ្យជាមួយ Houston Astros។ ចុចលើវីដេអូខាងក្រោម ដើម្បីស្តាប់សារលើកទឹកចិត្តរបស់គាត់!

WINTER COAT DRIVE (អាវរដូវរងា)

សម្រាប់ក្រុមគ្រួសារអ្នកមកថ្មីរបស់យើងភាគច្រើន នេះជាលើកដំបូងដែលពួកគេនឹងជួបប្រទះរដូវរងា New England។

ចូលរួមជាមួយក្រុម MLL ដើម្បីគាំទ្រដល់គ្រួសារអ្នកចំណូលថ្មីរបស់យើងដោយការទិញសម្លៀកបំពាក់រដូវរងាដ៏កក់ក្តៅសម្រាប់កុមារ និងមនុស្សវ័យជំទង់ចាប់ពីអាយុ 5 ដល់ 20 ឆ្នាំ។

សូមដាក់អំណោយក្នុងថង់។ នឹងមានប្រអប់ប្រមូលមួយនៅក្នុងឡប់ប៊ីនៃ 797 Westminster Street រហូតដល់ថ្ងៃសុក្រទី 16 ខែធ្នូ។

ទំនិញកំពុងប្រមូល (ថ្មីតែប៉ុណ្ណោះ)៖
- អាវរងា
- មួក
- កន្សែងរុំក
- ស្រោមដៃ
- ស្រោមជើង



មីនុយសាលារៀនខែធ្នូ

កូសសម្គាល់លើប្រតិទិនរបស់អ្នក!

- **ការកសាងឡើងវិញសាលារៀនសាធារណៈព្រូវីដិន វគ្គការចូលរួមសហគមន៍**
ថ្ងៃច័ន្ទ ទី 5 ខែធ្នូ
6:00 p.m. - 7:30 p.m.
- **សាកលវិទ្យាល័យមាតាបិតា៖ ញ៉ាំល្អ ចំណាយតិច**
ថ្ងៃពុធ ទី 7 ខែធ្នូ
6:00 p.m. - 7:30 p.m.
- **ការកសាងឡើងវិញសាលារៀនសាធារណៈព្រូវីដិន វគ្គការចូលរួមសហគមន៍**
ថ្ងៃព្រហស្បតិ៍ ទី 8 ខែធ្នូ
6:00 p.m. - 7:30 p.m.
- **សាកលវិទ្យាល័យមាតាបិតា៖ គាំទ្រអ្នកសិក្សាពហុភាសា**
ថ្ងៃអង្គារទី 13 ខែធ្នូ
6:00 p.m. - 7:30 p.m.
- **ការចេញមុនម៉ោង**
ថ្ងៃពុធ ទី 14 ខែធ្នូ
- **ថ្ងៃឈប់សម្រាក**
ថ្ងៃទី 23 ខែធ្នូ - ថ្ងៃទី 1 ខែមករា

រឿងអស្ចារ្យកំពុងកើតឡើងពេញមណ្ឌលសិក្សាធិការ យើងចង់ឱ្យអ្នកទាំងអស់គ្នាបានដឹងឮ! ប្រសិនបើអ្នកមានកម្មវិធី ព្រឹត្តិការណ៍ បុគ្គលិក ឬសិស្សដែលមានរឿងដ៏អស្ចារ្យដែលអ្នកចង់រំលេចឡើង សូមផ្ញើអ៊ីមែលទៅ communications@ppsd.org។

Providence Schools

© សាលារៀនសាធារណៈព្រូវីដិន 2022 · communications@ppsd.org · www.providenceschools.org